**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០៧២០ ព.ណ...អ.ព...

ថ្ងៃ ចន្ទ ៥ រោច ខែ ពិសាខ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនទូទៅឱ្យបានជ្រាបថា៖ ដើម្បីជំរុញសកម្មភាពពាណិជ្ជកម្មក្នុងស្រុក ឱ្យមានភាពរស់រវើក និងឱ្យកាន់តែប្រសើរឡើងនូវការទទួលស្គាល់ និងគាំទ្រផលិតផលខ្មែរ ស្របតាមយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញលើកកម្ពស់វិស័យពាណិជ្ជកម្ម និងការអភិវឌ្ឍន៍វិស័យឯកជន ក្រសួងពាណិជ្ជកម្ម នឹងបន្តរៀបចំយុទ្ធនាការទិញផលិតផលខ្មែររដូវកាលទី៧ តាមរយៈការដាក់តាំងបង្ហាញផលិតផលខ្មែរ និងផលិតផលបន្លែផ្លែឈើលើកទី១៥ ដែលនឹងប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី១៦-១៩ ខែមិថុនា ឆ្នាំ២០២២** នៅក្រុងសៀមរាប ខេត្តសៀមរាប។

ការរៀបចំព្រឹត្តិការណ៍នេះ ក្នុងគោលបំណងបង្កើនសកម្មភាពពាណិជ្ជកម្មនៅមូលដ្ឋាន ឱ្យមានភាពប្រទាក់ក្រឡាពីកសិដ្ឋានមកទីផ្សារ ជាវេទិកាផ្សារផ្គងរវាងអ្នកផលិត និងអ្នកត្រូវការផលិតផលយកទៅចែកចាយបន្ត និងបំផុសស្មារតីអ្នកប្រើប្រាស់ទូទៅ ឱ្យចូលរួមគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុកជំនួសឱ្យការនាំចូលពីបរទេសជាជំហានៗ។

ក្នុងឱកាសនេះ ក្រសួង សូមអញ្ជើញលោក លោកស្រី ជាផលិតករ ម្ចាស់កសិដ្ឋាន អ្នកកែច្នៃ សមាគមអាជីវកម្ម និងសហគមន៍ផលិតបន្លែ និងផ្លែឈើខ្មែរ ដែលត្រូវការស្តង់ដាក់តាំងផលិតផលសម្រាប់ស្វែងរកដៃគូបញ្ជាទិញ ឬមានគម្រោងចុះកិច្ចសន្យាទិញ-លក់ សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទីពីរ នៃអគារទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនង ៖ ០១២ ៧០៣ ៣៩៣ ឬ ០៧៧ ៣៣៩ ៤៣៩ ឬ ០៧៧ ៣៣២ ២៣៣
អាសយដ្ឋានអ៊ីមែល៖ sopheap.sok56789@gmail.com / neary86@gmail.com / vuthakep@yahoo.com

ឬ ទាក់ទងមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប៖ ទូរស័ព្ទលេខ ០១២ ៥៥០ ៦៣៥ / ០១២ ៩៦៦ ៤៦៦
អាសយដ្ឋានអ៊ីមែល៖ kimlyph@gmail.com

សម្គាល់៖ ក្រសួងពាណិជ្ជកម្ម សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីរៀបចំព្រឹត្តិការណ៍ខាងលើប្រសិនបើមានការចាំបាច់។

**សូមអរគុណ!**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
នាយកដ្ឋានកិច្ចការពិព័រណ៍

# ពាក្យសុំចុះឈ្មោះ
# ចូលរួមតាំងបង្ហាញផលិតផលខ្មែរ
# ពិធីតាំងបង្ហាញផលិតផលបន្លែ និងផ្លែឈើលើកទី១៥ ឆ្នាំ ២០២២

នៅខេត្តសៀមរាប ចាប់ពីថ្ងៃ១៦-១៩ ខែមិថុនា ឆ្នាំ២០២២

## ១.ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | |
| ឈ្មោះប្រធានក្រុមហ៊ុន | |
| អាសយដ្ឋានក្រុមហ៊ុន | |
| ទូរស័ព្ទ ឬទូរសារ | |
| អ៊ីម៉ែល | |

## ២.ព័ត៌មានអំពីប្រភេទផលិតផល

| ប្រភេទផលិតផល | | វាយមុខផលិតផល |
|---|---|---|
| កសិផល | ☐ | |
| ជលផល | ☐ | |
| ផលិតផលម្ហូបអាហារ | ☐ | |
| ផលិតផលភេសជ្ជៈ | ☐ | |
| ផលិតផលសិប្បកម្ម | ☐ | |
| ផលិតផលឧស្សាហកម្ម | ☐ | |
| គ្រឿងសង្ហារិម | ☐ | |
| សេវាកម្ម | ☐ | |

## ៣-លក្ខខណ្ឌនៃការចូលរួម

-ត្រូវរៀបចំស្តង់របស់ខ្លួនឱ្យបានរួចរាល់មួយថ្ងៃ មុនពេលបើកសម្ពោធពិព័រណ៍
-មិនអនុញ្ញាតឱ្យលក់ផលិតផលផ្សេងៗ ដែលមិនមានបំពេញនៅក្នុងបែបបទខាងលើ
-មិនអនុញ្ញាតផ្ទេរស្តង់ ឬក៏ទុកស្តង់ឱ្យនៅទំនេរក្នុងរយៈពេលនៃការតាំងពិព័រណ៍
-មិនអនុញ្ញាតឱ្យផ្សព្វផ្សាយផលិតផលដោយប្រើឧបករណ៍បំពងសំឡេងធំៗក្នុងបរិវេណពិព័រណ៍

ក្នុងករណីមិនបានអនុវត្តន៍ ដូចបានជម្រាបជូនខាងលើ គណៈកម្មការមានសិទ្ធិបិទស្តង់ ឬដកហូតស្តង់មកវិញ ហើយរាល់ការចំណាយសាងសង់ស្តង់ជាបន្ទុករបស់ម្ចាស់ស្តង់។

ខ្ញុំបាទ/នាងខ្ញុំ ជាប្រធាន/តំណាងក្រុមហ៊ុន សូមធានាអះអាងថានឹងអនុវត្តន៍តាមលក្ខខណ្ឌនៃការចូលរួម បើប្រាសចាកពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២២

**ប្រធាន/តំណាងក្រុមហ៊ុន**